# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ...៧៧... សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបន្ថែមសមាសភាព ក្នុងក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន ISLAND DEVELOPMENT GROUP INC.

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧
- យោងសេចក្តីសម្រេចលេខ ២៩ សសរ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះគំរោងជួល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម របស់ក្រុមហ៊ុន **ISLAND DEVELOPMENT GROUP INC.**
- អនុលោមតាមតំរូវការចាំបាច់

## សម្រេច

**ប្រការ១:** បន្ថែមសមាសភាព កងយោធពលខេមរភូមិន្ទ ជាសមាជិកក្នុងក្រុមការងារ ដើម្បីរៀបចំឯកសារគតិយុត្តិ និងពិនិត្យដោះស្រាយ ចំពោះតំរោងផ្លូល និងអភិវឌ្ឍន៍កោះរុង និងកោះរុងសន្លឹម ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ុល សារឿន** អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ សមាជិក

២- លោក ឧត្តមនាវីត្រី **អ៊ុក សីហា** មេបញ្ជាការមូលដ្ឋានសមុទ្រ សមាជិក

៣- លោក វរនាវីឯក **គ្រួច គីមថុន** នាយការិយាល័យទី៣ បញ្ជាការដ្ឋានជើងទឹក សមាជិក

៤- លោក វរនាវីទោ **ឃុន ប៊ុរិន្ទ** មេបញ្ជាការរងមូលដ្ឋានសមុទ្រ សមាជិក

**ប្រការ២:** ក្រៅពីការបន្ថែមសមាសភាព ដូចមានចែងក្នុងប្រការ១ ខាងលើ ខ្លឹមសារនៃសេចក្តីសំរេចលេខ ២៥ សសរ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០២ នៅរក្សាទុកជាធរមានដដែល ។

**ប្រការ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី - សហរដ្ឋមន្ត្រីក្រសួងក្រសួងមហាផ្ទៃ - សហរដ្ឋមន្ត្រីក្រសួងការពារជាតិ - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ - រដ្ឋមន្ត្រីក្រសួងទេសចរណ៍ - រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ - រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន - រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ - រដ្ឋមន្ត្រីក្រសួងបរិស្ថាន - ប្រធាន"ក.អ.ក" - រដ្ឋមន្ត្រីគ្រប់ក្រសួង - ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ